ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៥៧៤/១៩ គ.ជ.ប.ជ

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រីមាសទី១ និងទិសដៅត្រីមាសទី២ ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីកិច្ចខិតខំប្រឹងប្រែងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ បានសហការគ្នាផ្តល់ភាពស្របច្បាប់ជូនពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការងារបទដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ និងដំណើរការ

ក.១.១. គោលនយោបាយកំពុងរៀបចំ

- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។

### ក.១.២.សេចក្ដីព្រាងច្បាប់កំពុងរៀបចំ

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្ដីព្រាងច្បាប់៖
  - ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្ដីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

### ក.១.៣.សន្ធិសញ្ញាកំពុងរៀបចំ

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្ដីពី "ការបញ្ជូនទណ្ឌិត"។

### ក.១.៤.អនុស្សរណៈកំពុងរៀបចំ

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្ដីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី"។

### ក.១.៥.បទដ្ឋានគតិយុត្តកំពុងរៀបចំ

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីបេបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង

#### ខ.១.១.ការផ្សព្វផ្សាយដោយផ្ទាល់

ខ.១.១.១.ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ

នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានសរុបចំនួន ១៤.១២៣លើក មានអ្នកចូលរួមសរុបចំនួន ៧៥៦.៣៨០នាក់ (ប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៨ មានចំនួន ៨៩៧.១១៣នាក់ គឺមានការថយចុះចំនួន ១៤០.៧៣៣នាក់ ស្មើនឹង១៨.៦០% ក្នុងនោះស្ត្រីចំនួន ៤១៣.០៥៧នាក់ មានដូចតារាងលម្អិតខាងក្រោម៖

# តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ<br>ចំនួន ដង/លើក | ផ្សព្វផ្សាយ<br>ចំនួន មនុស្ស | ផ្សព្វផ្សាយ<br>ចំនួន ស្ត្រី | វេទិកាសាធារណៈ<br>ចំនួន ដង/លើក | វេទិកាសាធារណៈ<br>ចំនួន មនុស្ស | វេទិកាសាធារណៈ<br>ចំនួន ស្ត្រី |
|---|---|---|---|---|---|---|---|
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | ក្រសួងកិច្ចការនារី | ១២ | ២.៤២៤ | ១.៥០៨ | | | |
| ២ | ក្រសួងឧស្សាហកម្ម-សិប្បកម្ម | ១៤ | ៧៣ | ៣៨ | | | |
| ៣ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤០៥ | ៣៨.៥៥៨ | ១៧.៩៧៧ | | | |
| ៤ | កាកបាទក្រហមកម្ពុជា | ០២ | ៧៤ | ៧៤ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៤៣៣ លើក | ៤១.១២៩ នាក់ | ១៩.៥៩៧ នាក់ | | | |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | មិនមានរបាយការណ៍ | | | | | |
| ២ | ខេត្តកណ្តាល | ១៣២ | ៤.៥៩៩ | ២.៥៥៥ | ៥១២ | ២០.០៥០ | ៩.៩០៨ |
| ៣ | ខេត្តបាត់ដំបង | ១.៦៦៦ | ៩៥.៥២០ | ៥០.៧៧៨ | ៨១៨ | ៣៣.៨១៣ | ១៧.៤៩៤ |
| ៤ | ខេត្តពោធិ៍សាត់ | ៨៥១ | ៦១.៧១៦ | ៣៨.១០៣ | ៨៧៩ | ៤៦.៩២៥ | ២៦.០៩៨ |
| ៥ | ខេត្តសៀមរាប | ១.៧៣៥ | ៥៥.៩១៦ | ៣២.៩៩៨ | ៤៣៥ | ១៨.៣៥១ | ១០.៩១០ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.៥១៤ | ១១៤.៣៣៣ | ៦៣.០៤៥ | ១.០៨៩ | ៤៨.៤៦១ | ២៧.៥៤៨ |
| ៧ | ខេត្តកំពង់ចាម | ១.៩១៥ | ១០៤.៣៣៦ | ៥៨.៨៥៦ | ២៧៦ | ១៤.២២៣ | ៧.៣៣៧ |
| ៨ | ខេត្តព្រះសីហនុ | ៦៨ | ៣.១៨៩ | ១.៤៧៧ | ២០ | ១.០០៩ | ៥២១ |
| ៩ | ខេត្តព្រះវិហារ | ២០ | ៥.១៤១ | ១.៨៥៩ | ៨ | ១.៨៩៦ | ៦៥៩ |
| ១០ | ខេត្តស្វាយរៀង | ២៨ | ១៣៥ | ៧១ | ១.០៥៥ | ៤១.៩៥៩ | ២២.១៧១ |
| ១១ | ខេត្តប៉ៃលិន | ៣ | ៤៥ | ៣៥ | មិនមានរបាយការណ៍ | | |
| ១២ | ខេត្តកោះកុង | ៦ | ៨.៣៥៨ | ៣.៨៣០ | ១៤៩ | ៥.១៣៤ | ២.៤៨៨ |
| ១៣ | ខេត្តកំពត | ៨ | ២៧ | ១៤ | ៤៤ | ២.៣៥៣ | ១.៥២៤ |
| ១៤ | ខេត្តកំពង់ធំ | មិនមានរបាយការណ៍ | | | | | |
| ១៥ | ខេត្តតាកែវ | ៣២២ | ១៤.៤២១ | ៦.៨២៧ | ១៣ | ៤៦២ | ៣១៨ |
| ១៦ | ខេត្តក្រចេះ | មិនមានរបាយការណ៍ | | | | | |
| ១៧ | ខេត្តកែប | មិនមានរបាយការណ៍ | | | ១៩ | ៣.៧៣៩ | ១.៨៤៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៦ | ២.៧៧២ | ១.៣៥២ | មិនមានរបាយការណ៍ | | |
| ១៩ | ខេត្តស្ទឹងត្រែង | មិនមានរបាយការណ៍ | | | | | |
| ២០ | ខេត្តរតនគិរី | ៣៤ | ២.៦២១ | ១.០៨៦ | ៤៧ | ៣.៣០៤ | ១.៥៣២ |
| ២១ | ខេត្តព្រៃវែង | មិនមានរបាយការណ៍ | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៥ | ២៨៥ | ១២៧ | ៣ | ១៥៨ | ៩៦ |
| ២៣ | ខេត្តបន្ទាយមានជ័យ | មិនមានរបាយការណ៍ | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | មិនមានរបាយការណ៍ | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | មិនមានរបាយការណ៍ | | | | | |
| | សរុប រាជធានី-ខេត្ត | ៨.៣២៣លើក | ៤៧៣.៤១៤នាក់ | ២៦៣.០១៣នាក់ | ៥.៣៦៧លើក | ២៤១.៨៣៧នាក់ | ១៣០.៤៤៧នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ១៤.១២៣ លើក | | ចំនួនមនុស្សសរុប ៧៥៦.៣៨០ នាក់ | | ចំនួនស្ត្រី ៤១៣.០៥៧ នាក់ | |

### ខ.១.២.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមជាវាគ្មិន

#### ខ.១.២.១.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ និងតាមប្រព័ន្ធផ្សព្វផ្សាយ

- ខេត្តសៀមរាបៈ

មន្ទីរព័ត៌មាន បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីយើងធ្វើបាន និងកម្មវិធីសន្ទនាមតិ "**នាទីស្រុកយើង**" ដើម្បីឲ្យយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយធ្វើការផ្សាយផ្ទាល់ និងចាក់ផ្សាយឡើងវិញនៅវិទ្យុ FMជាតិនគរភ្នំ១០៣MHZ ទូរទស្សន៍ជាតិខេត្តសៀមរាប (ទូរទស្សន៍ខ្សែកាបអង្គរខេត្តសៀមរាប ប៉ុស្តិ៍លេខ៩៥) និងតាមប្រព័ន្ធអនឡាញ សរុបចំនួន ២.៦២៥លើក (ផ្សាយផ្ទាល់ ២៨លើក ចាក់ផ្សាយឡើងវិញ ៨៣លើក និងផ្សព្វផ្សាយស្ពតអប់រំ ២.៥១៤លើក)។

- ខេត្តតាកែវៈ

មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈកម្មវិធីវិទ្យុ បានចំនួន ៣៩លើក។

- ខេត្តកំពតៈ

បន្តជំរុញមន្ត្រីក្រុមលេខាធិការដ្ឋាននៅតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់ ឲ្យបន្តចាក់ផ្សាយឌីស "**ជើងមេឃនៅឯណា និងតម្លៃនៃកូនក្រមុំ**" នៅតាមរោងកាហ្វេ និងទីសាធារណៈ។

- ខេត្តកោះកុងៈ

បានចាក់ផ្សាយកម្មវិធីកិច្ចពិភាក្សាស្តីពី ជម្រើសដោយសុវត្ថិភាព តាមរយៈវិទ្យុសាគរកោះកុង នៃមន្ទីរព័ត៌មានខេត្ត ក្នុងនោះរួមមាន ៖ ការជួញដូរមនុស្ស ចំនួន ១.២០០លើក ការចំណាកស្រុកដោយសុវត្ថិភាព និងដោយប្រថុយប្រថាន ចំនួន ១៥០លើក។

#### ខ.១.២.២.ការចូលរួមជាវាគ្មិន

- ថ្នាក់ជាតិ
  - គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ ស្តីពីអំពើហិង្សាផ្លូវភេទទៅលើកុមារ រៀបចំសម្របសម្រួលដោយអង្គការសីលការ(SILAKA) មានសមាសភាពចូលរួមចំនួន ៤៦នាក់ (ស្រី ៣៣នាក់) នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។

- ថ្នាក់ក្រោមជាតិ
  - ខេត្តបាត់ដំបងៈ បានធ្វើជាវាគ្មិនផ្សព្វផ្សាយការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ចំនួន ០៥ស្រុកៈ
    - ស្រុកថ្មគោល រៀបចំដោយអង្គការ OCE អ្នកចូលរួមចំនួន ៤១នាក់ (ស្រី ២៦នាក់)
    - ស្រុកសំឡូត រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ១៣នាក់)
    - ស្រុកកំរៀង រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ២៥នាក់ (ស្រី ១០នាក់)
    - ស្រុកភ្នំព្រឹក រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៧នាក់)
    - ស្រុកសំពៅលូន រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ១៤នាក់)។

- ខេត្តសៀមរាបៈ
  - បានសម្របសម្រួលជូនក្រុមការងារបច្ចេកទេសទទួលជួបអង្គការដៃគូ និងចូលរួមជាវាគ្មិនពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៤លើក។
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមធ្វើជាវាគ្មិនស្តីពី ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ចំនួន ០៤លើក។
- ខេត្តកំពតៈ

បានចូលរួមជាវាគ្មិនក្នុងកម្មវិធី "**យើងធ្វើបាន**" នៅវិទ្យុFM ៩៩.៧០MHZ ចំនួន ០១លើក។

- ខេត្តកំពង់ចាមៈ

មន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធី "**យើងធ្វើបាន**" នៅវិទ្យុFM ៩៩.៧០ MHZ ចំនួន ០១លើក លើប្រធានបទការសម្របសម្រួល និងអន្តរាគមន៍ប្រជាពលរដ្ឋរងគ្រោះដោយការធ្វើចំណាកស្រុកខុសច្បាប់។

- ខេត្តក្រចេះ៖

បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ "**អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ**" តាមរយៈការផ្សាយសម្លេង និងការឡាយតាមគេហទំព័រហ្វេសប៊ុករបស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមរយៈវិធានការជំនាញ

### ខ.២.១.វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក)

#### ខ.២.១.១.ការគ្រប់គ្រងជនបរទេស

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:</u> ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ២៧២លើក មនុស្សចំនួន ៥៦៩នាក់ (ស្រី ៩៦នាក់) ត្រូវបានបណ្តេញចេញដោយៈ

- ប្រកាសក្រសួងមហាផ្ទៃ ១២៤លើក មនុស្សចំនួន ៣៤៨នាក់ (ស្រី ៩៦នាក់)។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ១៤៨លើក មនុស្សចំនួន ២២១នាក់។

២. <u>ករណីស្នាក់នៅខុសច្បាប់</u>

- ប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ ០៧លើក មនុស្សចំនួន ០៧នាក់ មាន០៧សញ្ជាតិ គឺសញ្ជាតិប៉ាគីស្ថាន នីហ្សេរីយ៉ា ស៊ុយអែត អាល្លឺម៉ង់ ក្រូអាត ចិន និងឡាវ។
- ប្រើប្រាស់លិខិតឆ្លងដែនមិនប្រក្រតី ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិអង់គ្លេស។
- ស្នាក់នៅលើសទិដ្ឋាការ ០១លើក មនុស្ស ០១នាក់ សញ្ជាតិប៉ាគីស្ថាន
- គ្មានឯកសារគ្រប់គ្រាន់ ០២លើក មនុស្សចំនួន ១២នាក់(ស្រី០២នាក់) សញ្ជាតិវៀតណាម ១០នាក់ និងចិន ០២នាក់។
- ហួសទិដ្ឋាការស្នាក់នៅ ០២លើក មនុស្សចំនួន ០២នាក់ សញ្ជាតិកូរ៉េ និងអាល្លឺម៉ង់។

៣. <u>ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី</u>

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ សរុបមនុស្សចំនួន ៩៣នាក់ (ស្រី ៤៥នាក់) សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារបានចំនួន ៦៧ឯកសារ។

### ខ.២.១.២.ការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងត្រីមាសទី១ ឆ្នាំ២០១៩ នេះ មានតួលេខដូចខាងក្រោម៖

***<u>តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុក</u>***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣៧១.៥៤៧ | ១៦១.២២៣ | ៩.៣៥៦ | ៣.៥៣២ | ២១០.០៨៥ | ៩៥.៣៩០ | ៦៥៤ | ២៧៧ | ១៦១.៤៦២ | ៦៥.៨៣៣ | ៨.៧០២ | ៣.២៥៥ | កើនឡើង ៦៤ |
| កុម្ភៈ | ៣៦៣.៣៥៧ | ១៥៩.៣៨៧ | ១០.២៨០ | ៣.៨២២ | ២០២.៨៨៤ | ៩៤.០០៨ | ១.៥៧៩ | ៥៦២ | ១៦០.៤៧៣ | ៦៥.៣៧៩ | ៨.៧០១ | ៣.២៦០ | ថយចុះ ៨.១៩០ |
| មីនា | ៣៥៨.៩១៣ | ១៥៩.១៤១ | ១០.៥៥៣ | ៤.០៨៧ | ២០៨.៧២៧ | ៩៤.០២០ | ១.៩២៦ | ៨៦៥ | ១៥០.១៨៦ | ៦៥.១២១ | ៨.៦២៧ | ៣.២២២ | ថយចុះ ៤.៤៤៤ |

• **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារ ព្រំដែនគោកវរៈសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ១៣២លើក ពុំបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។

### ខ.២.២.វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត(ខេត្ត តាកែវ កែប មណ្ឌលគិរី ក្រចេះ កំពង់ចាម ឧត្តរមានជ័យ រតនគិរី បន្ទាយមានជ័យ សៀមរាប និងខេត្តស្វាយរៀង) បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម៖

**ការធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់**
**ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ៖**

| ត្រីមាសទី១ ឆ្នាំ២០១៩ | | | |
|---|---|---|---|
| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា |
| ចំនួនគោលដៅ | ៥៦៣ គោលដៅ | ៥៥១ គោលដៅ | ៤៦៩ គោលដៅ |
| ចំនួនមនុស្ស | ២.២៤២នាក់(ស្រី ១.៧៩៧នាក់) | ៣.១៩៧នាក់(ស្រី ២.២៩២នាក់) | ១.៩៣៥នាក់(ស្រី១.៦២០នាក់) |

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន **៧៥**គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
- ស្នងការដ្ឋាននគរបាលខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ១០៧លើក នៅខេត្តក្រចេះ ស្ទឹងត្រែង កំពង់ស្ពឺ ព្រះវិហារ ស្វាយរៀង និងខេត្តព្រៃវែង។

**ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ**

| ស្នងការដ្ឋានរាជធានី-ខេត្ត | ត្រីមាសទី១ ឆ្នាំ២០១៨ | | |
|---|---|---|---|
| | ខែមករា | ខែកុម្ភៈ | ខែមីនា |
| | ៣៥ លើក | ៣៩ លើក | ៣៣ លើក |
| សរុប | ១០៧ លើក | | |

### ខ.២.៣.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសសរុបចំនួន ៥២៩គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ៣៨នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ខ.៣. កិច្ចការពារកុមារ

- ខេត្តសៀមរាប៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចពលកម្មកុមារ នៅក្នុងវិស័យឡឥដ្ឋ នៅស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំ ដោយក្រុមការងារបានចែកជូនសេចក្តីប្រកាសព័ត៌មាន ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ និងផ្សព្វផ្សាយផលប៉ះពាល់ នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានពិនិត្យទៅលើបច្ចេកទេស និងការប្រើប្រាស់កម្លាំងពលកម្ម (ពិសេសពលកម្មកុមារ) បន្ទាប់មកបានធ្វើការណែនាំដល់ម្ចាស់សហគ្រាស ឲ្យមានការប្រុងប្រយ័ត្នចំពោះកុមារដែលធ្វើការនៅក្នុងទីតាំងឡឥដ្ឋរបស់ខ្លួន។

- ខេត្តកំពង់ធំ៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ច វាយតម្លៃកន្លែងថែទាំជំនួសចំពោះកុមារកំព្រាងាយរងគ្រោះដោយអំពើហឹង្សា ការធ្វើចំណាកស្រុក ការជួញដូរ ការរំលោភ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងទីទ័លក្រ បានចំនួន ៣១កន្លែង កុមារ ៨៩២នាក់ (ស្រី ៤៥២នាក់) ក្នុងនោះ៖

- មណ្ឌលថែទាំ ចំនួន ១០មណ្ឌល កុមារ ៣៨៩នាក់ (ស្រី ១៨០នាក់)
- កន្លែងថែទាំសហគមន៍ ចំនួន ១៧កន្លែង កុមារ ២៨៩នាក់ (ស្រី ១៣២នាក់)
- កន្លែងអន្តរវិសិកដ្ឋាន ចំនួន ០៣កន្លែង កុមារ ២១១នាក់ (ស្រី ១៣៩នាក់)
- ផ្ទះសហគមន៍គ្រួសារធម៌ ចំនួន ០១កន្លែង កុមារ ០៣នាក់ (ស្រី ០១នាក់)។

- ខេត្តព្រះសីហនុ៖

ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ និងផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

- ខេត្តរតនគិរី៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន ១៣លើក និងចុះធ្វើអធិការកិច្ចពិសេសចំនួន ០៨លើក និងអធិការកិច្ចពិសេសក្រៅកម្មវិធី ០២លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពីការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ និងការប្រើប្រាស់ពលកម្មកុមារ។

- ខេត្តប៉ៃលិនៈ

  បានចុះអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់ នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា រោងសម្ងួត និងថ្លឹងកសិផល កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ១៦០កន្លែង។

- ខេត្តស្វាយរៀងៈ

  កម្លាំងអធិការដ្ឋាននគរបាលក្រុង បានចុះស្រង់ទិន្នន័យគោលដៅរោងចក្រ សហគ្រាស សិប្បកម្មសង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារចំនួន ០១លើក ស្មើ ០២គោលដៅ មានកម្មករសរុបចំនួន ៦០នាក់(នីតិជនទាំងអស់) និងបានណែនាំ និងធ្វើកិច្ចសន្យាដល់ម្ចាស់សិប្បកម្មទាំងអស់កុំឲ្យទទួលយកកុមារ(អនីតិជន)មកធ្វើការ។

### ខ.៤. ការលើកកម្ពស់ជីវភាព

- ខេត្តសៀមរាប

  **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងអង្គការសេដាក** សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយ កសិករឲ្យយល់ដឹងអំពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបណ្តុះបណ្តាលការងារធ្វើកសិកម្មធម្មជាតិជាលក្ខណៈគ្រួសារ នៅក្នុងស្រុកគោលដៅចំនួន០៦ (ស្រុកស្រីស្នំ វ៉ារិន សូទ្រនិគម ជីក្រែង អង្គរជុំ និងស្រុកពួក) មាន ១១ឃុំ និង ៦១ភូមិ សរុបបាន ១០លើក អ្នកចូលរួមចំនួន ៤៣នាក់(ស្រី ៣១នាក់)។

### ខ.៥. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ

- ថ្នាក់ក្រោមជាតិ

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ២២.១០០ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ
  - ខេត្តបាត់ដំបង ចំនួន ១៣.៩៥៧ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ៦.១៥៤ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ១.៩៨៩ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីអង្គភាពៈ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តចំនួន ១៤ រួមមាន រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល មណ្ឌលគិរី ព្រៃវែង ក្រចេះ សៀមរាប ព្រះសីហនុ និងខេត្តត្បូងឃ្មុំ។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន ៤២ករណី (បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៨ ចំនួន ៣៤ករណី មានការកើនឡើង ០៨ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៥៥នាក់/៤៦នាក់(ស្រី ០៩នាក់ អនីតិជន ០៤នាក់ ជនបរទេស ១៣នាក់ សញ្ជាតិចិន ១២នាក់ និងអាមេរិក ០១នាក់)។ សង្គ្រោះជនរងគ្រោះ ចំនួន ១៥៧នាក់/៦០នាក់

ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ៣៦នាក់ អាយុ១៥-១៧ឆ្នាំ ១៩នាក់ និងអាយុ១៨ឆ្នាំឡើង ១០២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ៣៤នាក់ និងប្រគល់ទៅគ្រួសារ ១២៣នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងបូកសរុបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទប្រចាំខែនីមួយៗ*

| ល.រ | បរិយាយ | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| ១ | ខែមករា | ១៤ | ៧៤ | ១៦ | ចិន ១ |
| ២ | ខែកុម្ភៈ | ០៩ | ៣៦ | ១៦ | ចិន ៧ |
| ៣ | ខែមីនា | ១៩ | ៤៧ | ២៣ | ចិន៤ អាមេរិក១ |
| សរុបត្រីមាសទី១ | | ៤២ ករណី | ១៥៧ នាក់ | ៥៥ នាក់ | ១៣ នាក់ |

**គ.១.១.១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០៤ករណី/០៩ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៦នាក់/១០នាក់(ស្រី ០៣នាក់ ជនបរទេស ០១នាក់ សញ្ជាតិអាមេរិក)។ សង្គ្រោះជនរងគ្រោះចំនួន ៦០នាក់ ក្នុងនោះមាន អាយុ-១៥ឆ្នាំ ០៩នាក់ អាយុ១៥-១៧ឆ្នាំ ១២នាក់ និងអាយុ១៨ឆ្នាំឡើង ៣៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៥នាក់ និងឲ្យគ្រួសារ ៥៥នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ | ០១ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ៥៣ | ០៤ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០៥ | ០១ | អាមេរិក ១ |
| *សរុប* | *០៤ ករណី* | *៦០ នាក់* | *០៦ នាក់* | *០១ នាក់* |

**គ.១.១.២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ៣៨ករណី/២៥ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ៤៩នាក់/៣៦នាក់(ស្រី ០៦នាក់ អនីតិជន ០៤នាក់ ជនបរទេស ១២នាក់ សញ្ជាតិចិន)។ សង្គ្រោះជនរងគ្រោះចំនួន ៩៧នាក់ ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ២៧នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ អាយុ១៨ឆ្នាំឡើង ៦៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២៩នាក់ និងប្រគល់ទៅគ្រួសារ ៦៨នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០៦ | ២៥ | ១០ | ចិន ៥ |
| -សញ្ចារកម្ម(មានអនីតិជន) | ០២ | ០៨ | ០២ | |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០១ | ២៧ | ០៧ | ចិន ៧ |
| -សញ្ចារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ ) | ០៤ | ១២ | ០៥ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៧ | ១៧ | ១៧ (អនី.២) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៨ | ០៨ | ០៨ (អនី.២) | |
| *សរុប* | *៣៨ ករណី* | *៩៧ នាក់* | *៤៩ នាក់* | *១២ នាក់* |

## គ.២. កិច្ចការយុត្តិធម៌

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់ពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការមានដូចខាងក្រោម៖

### គ.២.១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៤២ករណី ជនរងគ្រោះចំនួន ៥៤នាក់ (ស្រី ៤៥នាក់) អនីតិជន ៣៦នាក់ (ស្រី ៣០នាក់) ជនត្រូវចោទមានចំនួន ៤៧នាក់ (ស្រី ១២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣១ករណី តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន ១១ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ៣ | ១៥ | ៦ | ៣០ | ៣៥ | ១២ | ០ | ០ | ៣១ | ០ | ១១ |
| ៤២ | ១៨ នាក់ | | ៣៦ នាក់ | | ៤៧ នាក់ | | ០ | | ៤២ ករណី | | |

### គ.២.២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន ៦៥ករណី ជនរងគ្រោះចំនួន ៧៨នាក់ (ស្រី ៦៥នាក់) អនីតិជន ៥០នាក់(ស្រី ៤២នាក់) ជនត្រូវចោទមានចំនួន ៧៦នាក់ (ស្រី ១៤នាក់) នៅក្នុងឃុំចំនួន ៦២នាក់(ស្រី ០៩នាក់) នៅក្រៅឃុំចំនួន ១៤នាក់(ស្រី ០៥នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន ១៣ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន ៥២ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពង់ចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ៥ | ២៣ | ៨ | ៤២ | ៥៣ | ១៤ | ៩ | ០ | ៥៣ | ៩ | ០ | ០ | ០ | ៥ | ៩ | ០ | ១៣ | ០ | ៥២ |
| ៦៥ | ២៨ នាក់ | | ៥០ នាក់ | | ៦៧នាក់ | | ៩ នាក់ | | ៦២ នាក់ | | | | ១៤ នាក់ | | | | ៦៥ ករណី | | |

### គ.២.៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ៥១ករណី ជនរងគ្រោះចំនួន ៧៩នាក់ (ស្រី ៦៤នាក់) អនីតិជន ១២នាក់(ស្រី ៤៩នាក់) ជនជាប់ចោទសរុប ៦៩នាក់(ស្រី ១១នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ១៧ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៥៦នាក់ នៅក្រៅឃុំ ១៣នាក់ និងកំពង់ចាត់ការ ៣៤ករណី) ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| សរុប | ប | ស | ប | ស | ប | ស | ០ | ០ | ០ | ០ | ១៧ | ក្នុងឃុំ | ក្រៅឃុំ | |
| ៥១ | ៣ | ១៥ | ១២ | ៤៩ | ៥៨ | ១១ | | | | | | ៥៦ | ១៣ | ៣៤ |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ៧.២៨៣នាក់ (ស្រី ៣.១២៨នាក់) ក្នុងនោះមានៈ

- ប្រទេសថៃ ចំនួន ៧.២១៩នាក់ (ស្រី ៣.០៧៨នាក់)
- ប្រទេសវៀតណាម ចំនួន ៤០នាក់ (ស្រី ២៧នាក់)
- ប្រទេសចិន ចំនួន ១៩នាក់ (ស្រី ១៩នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន ០២នាក់ (ស្រី ០២នាក់)
- ប្រទេសសិង្ហបុរី ចំនួន ០២នាក់ (ស្រី ០២នាក់)
- ប្រទេសឡាវ ចំនួន ០១នាក់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានា សរុបចំនួន ៥៥នាក់ (ស្ត្រី ៣៨នាក់ កុមារ ១៤នាក់) ដូចមានតារាងលម្អិតប្រចាំខែនីមួយៗ៖

| ល.រ | បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ត្រីមាសទី១ |
|---|---|---|---|---|---|
| ១ | ចំនួនមនុស្ស | ១៤ នាក់ | ០៧ នាក់ | ៣៤ នាក់ | ៥៥ នាក់ |
| ២ | ចំនួនស្ត្រី | ១៤ នាក់ | ០៤ នាក់ | ២០ នាក់ | ៣៨ នាក់ |
| ៣ | ចំនួនកុមារ | ០១ នាក់ | ០៣ នាក់ | ១០ នាក់ | ១៤ នាក់ |

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ២១នាក់(ប្រុស ០៤នាក់ ស្ត្រី ០៦នាក់ កុមារា ០៥នាក់ កុមារី ០៦នាក់)។
- ក្រុមការងារការពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ អង្គការរតនៈអន្តរជាតិ អង្គការសួននៃក្តីសង្ឃឹមនៃកម្ពុជា និងអង្គការមេត្រីអន្តរជាតិ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន ៣៤នាក់(ស្ត្រី ៣១នាក់ កុមារា ០១នាក់ កុមារី ០២នាក់) មានប្រទេសចិន ២៦នាក់ វៀតណាម ០៤នាក់ ម៉ាឡេស៊ី ០៤នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ៣០នាក់ និងជួញដូរកម្លាំងពលកម្ម ០៤នាក់)។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលពលករខ្មែររងគ្រោះ ដែលត្រឡប់ពីបណ្តាប្រទេសផ្សេងៗសរុបចំនួន ២៧នាក់ (ស្រី) ក្នុងនោះ៖ មកពីប្រទេសចិន២៥នាក់ និងប្រទេសម៉ាឡេស៊ី ០២នាក់ តាមការសម្ភាសបានឲ្យដឹងថា ក្នុងនោះទៅតាមរយៈមេខ្យល់ ២៦នាក់ និងតាមក្រុមហ៊ុន ០១នាក់។

▪ អគ្គនាយកដ្ឋានអន្តោប្រវេសន៍

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ២៥៥លើក មនុស្សចំនួន ៣.៥០៧នាក់ (ស្រី ១.១៤៥នាក់ កុមារ ៣៦៣នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មនុស្សចំនួន ២២៥នាក់ (ស្រី ៧២នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មនុស្សចំនួន ៣.២៧៩នាក់ (ស្រី១.០៧៣នាក់ កុមារ ៣៦៣នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម មនុស្សចំនួន ០២នាក់
- និងមកពីប្រទេសឡាវ មនុស្សចំនួន ០១នាក់។

• **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន៤ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម សរុបចំនួន ១៨២លើក មនុស្សចំនួន ៣.៣៨៦នាក់ (ស្រី ១.១២៤នាក់ អនីតិជន ៤១៩នាក់) មានដូចតារាងលម្អិតប្រចាំខែនីមួយៗ៖

| ល.រ | បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ត្រីមាសទី១ |
|---|---|---|---|---|---|
| ១ | ចំនួនលើក | ៦៩ | ៥៨ | ៥៥ | ១៨២ |
| ២ | ចំនួនមនុស្ស | ១.១៩២ | ១.០៧១ | ១.១២៣ | ៣.៣៨៦ |
| ៣ | ចំនួនស្រី | ៤០២ | ៣៤០ | ៣៨២ | ១.១២៤ |

-ខេត្តបន្ទាយមានជ័យ ចំនួន ១៥១លើក មនុស្សចំនួន ៣.១៨០នាក់ (ស្រីចំនួន ១.០៦៤នាក់) អនីតិជនចំនួន ៤០១នាក់។

-ខេត្តបាត់ដំបង ចំនួន ២៣លើក មនុស្សចំនួន ១៤៩នាក់ (ស្រីចំនួន ៣៥នាក់)។

-ខេត្តកោះកុង ចំនួន ០៦លើក មនុស្សចំនួន ២៧នាក់ (ស្រីចំនួន ០៣នាក់)។

-ខេត្តស្វាយរៀង ចំនួន ០២លើក មនុស្សចំនួន ៣០នាក់ (ស្រីចំនួន ២២នាក់) អនីតិជនចំនួន១៨នាក់។

**ឃ.១.២.ការទទួលសាកសពបញ្ជូនត្រឡប់**

▪ អគ្គនាយកដ្ឋានអន្តោប្រវេសន៍

តាមទិន្នន័យរបស់សមត្ថកិច្ចតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ បានទទួលសាកសពពលរដ្ឋខ្មែរដែលបានស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ សរុបចំនួន ១៤សព(ស្រី ០១) ក្នុងខេត្តបន្ទាយមានជ័យ ចំនួន ០៤សព(ស្រី ០១) និងខេត្តបាត់ដំបង ចំនួន ១០សព។

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ១១៣នាក់(ស្ត្រី ៦៦នាក់ កុមារ ៣៤នាក់) ដូមមានតារាងលម្អិតប្រចាំខែនីមួយៗ៖

| ល.រ | បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ត្រីមាសទី១ |
|---|---|---|---|---|---|
| ១ | ចំនួនមនុស្ស | ៣១ នាក់ | ២៩ នាក់ | ៥៣ នាក់ | ១១៣ នាក់ |
| ២ | ចំនួនស្ត្រី | ២៤ នាក់ | ១៤ នាក់ | ២៨ នាក់ | ៦៦ នាក់ |
| ៣ | ចំនួនកុមារ | ០៥ នាក់ | ១២ នាក់ | ១៧ នាក់ | ៣៤ នាក់ |

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៦៣នាក់ (ស្ត្រី ១៦នាក់ កុមារ ៣៤នាក់) និងបានបញ្ជូនទៅអង្គការលុបបំបាត់ការជួញដូរមនុស្សសតវត្សទី២១(A21) អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការក្តីសង្ឃឹមពិភពលោក អង្គការក្តីស្រឡាញ់គ្មានព្រំដែន ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- មន្ត្រីជំនាញរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានសម្ភាសផ្តល់សេវាពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២១នាក់(ស្ត្រី) ទៅទទួលសេវានៅអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា អង្គការតេនះអន្តរជាតិ និងអង្គការបេសកកម្មអន្តរជាតិ(IJM)។
- មន្ទីរ ស.អ.យ រាជធានីភ្នំពេញ និងខេត្តសៀមរាប បានផ្តល់សេវា និងប្រឹក្សាយោបល់រួចបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២៩នាក់ ទៅទទួលសេវាបន្តនៅអង្គការដៃគូ។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យទៅតាមសហគមន៍វិញ សរុបចំនួន ០៤នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០២នាក់ និងករណីរំលោភសេពសន្ថវៈ ០២នាក់)។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការ(RIM SWAT) បើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើអាវុធ។ | ០២ | ៤០ | ០៣ |
| ២ | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង<br>- បានសហការជាមួយអង្គការ(ឆាលហ្វាន់) បើកវគ្គបណ្តុះបណ្តាលចំនួន ០២វគ្គ ស្តីពីកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ អ្នកចូលរួមចំនួន ៧៣នាក់ ស្រី ២២នាក់។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រុមហ៊ុនចំនួន១៣ នៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេសនានាក្នុងខេត្ត បើកវគ្គ | ០៦ | ៣៤១ | ១៦៤ |

| | | | | |
|---|---|---|---|---|
| | បណ្តុះបណ្តាលចំនួន ០៤វគ្គ ស្តីពីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមចំនួន ២៦៨នាក់ ស្រី ១៤២នាក់។ | | | |
| ៣ | **ខេត្តកោះកុង** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស។ | ០១ | ២៤ | ១២ |
| ៤ | **ខេត្តកំពត** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកស្វែងរកការងារធ្វើប្រកបដោយសុវត្ថិភាព និងស្របច្បាប់។ | ០២ | ៦៤ | ៤៩ |
| សរុប | | ១១ វគ្គ | ៤៦៩ នាក់ | ២២៨ នាក់ |

## ក.២. សិក្ខាសាលា

### ក.២.១.សិក្ខាសាលាក្នុងប្រទេស

តារាងរៀបចំបើកសិក្ខាសាលា

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ក្រសួងអប់រំ យុវជន និងកីឡា** បានរៀបចំសិក្ខាសាលាស្តីពីការពង្រឹង សមត្ថភាពលើក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរៀបចំផែនការបង្ការទប់ ស្កាត់អំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ នៅខេត្តកំពង់ឆ្នាំង។ | ០១ | ៦៥ | ០៩ |
| ២ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមការឧបត្ថម្ភរបស់អង្គការយូនីសេហ្វ។ | ០១ | ១២១ | ៤៥ |
| ៣ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសហការជាមួយអង្គការ( Hope for justice ) បើកវគ្គសិក្ខាសាលា ស្តីពីការជួញដូរមនុស្សនាសម័យទំនើប នៅសណ្ឋាគារកាំបូឌីយ៉ាណា។ | ០១ | ៧០ | ៥០ |
| ៤ | **ខេត្តបាត់ដំបង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ជនបរទេស ឬជនបរទេស ដែលប្រកបមុខរបរណាមួយនៅបណ្តាស្រុកជាប់ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបាត់ដំបង នៅក្នុងបរិវេណសាលាស្រុកភ្នំព្រឹក។ | ០១ | ១០០ | ០៥ |
| | សរុប | ០៤ វគ្គ | ៣៥៦ នាក់ | ១០៩ នាក់ |

### ក.២.២.សិក្ខាសាលាក្រៅប្រទេស

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  បានចាត់មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី០៩ ស្តីពីសំណាញ់ឯកភាពឆ្ពោះទៅមុខនៃការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

## ខ. កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈជាតិ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស( គ.ជ.ប.ជ )
  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ **បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង៖**
  - ស្តីពីយន្តការនៃការគ្រប់គ្រងមណ្ឌលទទួលពលករបញ្ជូនត្រឡប់ដោយអាជ្ញាធរថៃ និងប្រកាសផ្សព្វផ្សាយអំពីសេចក្តីសម្រេចលេខ ១៦៨/១៧ សសរ ស្តីពីការបង្កើតក្រុមការងារទទួលពលករ

ពលការិនីកម្ពុជាខុសច្បាប់មកពីប្រទេសថៃ និងសេចក្ដីសម្រេចលេខ ២០៩/១៨ សសរ ស្ដីពីការបង្កើតក្រុមការងារចម្រុះប្រចាំការទទួលពលករ ពលការិនីកម្ពុជាបញ្ជូនមកពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ។

- ស្ដីពីការកែសម្រួលខ្លឹមសាររបាយការណ៍ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៣លើក។
- ដើម្បីឆ្លើយតបសំណួររបស់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ក្នុងការរៀបចំបទបង្ហាញក្នុងកិច្ចប្រជុំទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសថៃ។
- ពិនិត្យតារាងសកម្មភាព នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ(បន្តបញ្ចប់) និងបន្ថែមការកែសម្រួលបំពេញចន្លោះ ដែលត្រូវការទិន្នន័យតាមចំណុចនៃការងារពាក់ព័ន្ធក្រុមនីមួយៗ អ្នកចូលរួមចំនួន ១៤នាក់ ស្រី ០៤នាក់។
- ពិនិត្យលទ្ធផល និងការផ្ដល់ពិន្ទុ នៃការវាយតម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គ.រ.ប.ជ/គ.ខ.ប.ជ អ្នកចូលរួមចំនួន ២១នាក់ (ស្រី ០៣នាក់)។

**បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង (នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ)៖**

- ស្ដីពីការពិគ្រោះយោបល់សម្រាប់ការរៀបចំកិច្ចប្រជុំពិភាក្សាលើកទី២ ស្ដីពី "ប្រទេសបញ្ជូនកម្ពុជា ឡាវ ភូមា" អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ០៥នាក់)។
- ស្ដីពីការរកវិធានការគ្រប់គ្រងលំហូរពលករកម្ពុជា អំឡុងពេលមកចូលរួមអបអរក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងពេលត្រឡប់ទៅវិញ។
- ស្ដីពីករណីពលករកម្ពុជាចំនួន ០២នាក់ បានស្លាប់ក្នុងពេលបំពេញការងារនៅប្រទេសថៃកាលពីឆ្នាំ២០១៧ អ្នកចូលរួមចំនួន ១៤នាក់ (ស្រី ០៤នាក់)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) បានរៀបចំកិច្ចប្រជុំ៖**
  - ស្ដីពីការធ្វើបច្ចុប្បន្នភាពទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ជាមួយអង្គការដៃគូ និងមន្ត្រីជំនាញបច្ចេកទេស ចំនួន ០២លើក។
  - ស្ដីពីការធ្វើបច្ចុប្បន្នភាពទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស លើកទី៥ ជាមួយមន្ត្រីជំនាញរបស់នាយកដ្ឋាន និងអង្គការដៃគូ។

## ➢ កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ

- **ខេត្តព្រះវិហារ**

រដ្ឋបាលខេត្ត និងសមត្ថកិច្ចច្រកទ្វារព្រំដែនតំបន់អានសេះ បានជួបប្រជុំជាមួយភាគីថៃ ស្ដីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្ដោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងការងារធ្វើក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ចំនួន០១លើក មនុស្សចូលរួមចំនួន ៣៨នាក់ នៅខេត្តព្រះវិហារ។

## ➢ កិច្ចប្រជុំក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាគណៈប្រតិភូរបស់កម្ពុជា ក្នុងកិច្ចប្រជុំពិភពលោកឆ្នាំ២០១៩ ស្ដីពី "សន្តិភាព សន្តិសុខ និងការអភិវឌ្ឍធនធានមនុស្ស" នាទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ នៅក្នុងកិច្ចប្រជុំនេះ

មានការចូលរួមពី ប្រមុខរដ្ឋ និងអតីតប្រមុខរដ្ឋ សមាជិកសភា សមាជិកព្រឹទ្ធសភា មេដឹកនាំស្ត្រី និង មេដឹកនាំសង្គមស៊ីវិល រៀបចំដោយសហព័ន្ធសន្តិភាពសកល(UPF) ដែលជាអង្គការសហប្រជាជាតិ ឆ្នាំ២០១៩។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**
  បានចូលរួមកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី១៣ និងការពិនិត្យឡើងវិញនូវយុទ្ធនាការស៊ើបអង្កេតរួមគ្នារបស់ខមមីតឆ្នាំ២០១៨ នៅទីក្រុងណាននចាង សាធារណរដ្ឋប្រជាមានិតចិន។
- **ក្រសួងកិច្ចការនារី**
  លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការស្រួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីត បានដឹកនាំគណៈប្រតិភូកម្ពុជា មានថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចំនួន ០២រូប ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គស្នងការដ្ឋាននគរបាលជាតិ អង្គការ UNACT និងអង្គការចាប់ដៃ សរុបចំនួន ១៤រូប (ស្រី ០៧រូប) ដើម្បីទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១៣ និងពិនិត្យមើលឡើងវិញនូវសកម្មភាពស៊ើបអង្កេតរួមគ្នារវាងប្រទេសសមាជិកទាំង៦ (COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13 ) នៅខេត្តជាំងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
  បានចាត់បញ្ជូនថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ចំនួន ០២រូប និង Cambodia Acts ០២រូប អង្គការ Cambodia Acts ០១រូប និងអង្គការជាសមាជិករបស់ Cambodia Acts ០៥រូប សរុបចំនួន ១០រូប (ស្រី ០៩រូប) ទៅចូលរួមកិច្ចប្រជុំ Reflection Between Cambodia-Thai (Annual Cross Border Meeting Between Cambodia and Thailand) នៅខេត្តត្រាត និងខេត្តរ៉ាក់យ៉ង ប្រទេសថៃ។

## ខ.២. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**
  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការ ហេបភីទ្រី ដែលមានលោក **Jerry Vong** ជាប្រធានដើម្បីសិក្សា រកចំណុចដែលអាចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងការចូលរួមជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

## ខ.៣. ទស្សនកិច្ចក្នុងប្រទេស និងក្រៅប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**
  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចុះទស្សនកិច្ចការងារដល់ទីតាំងទទួលពលករ និងបានជួបប្រជុំពិភាក្សាការងារដើម្បីពង្រឹងកិច្ចសហការ រវាងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូក្នុងការងារទទួល និងផ្តល់សេវា ដល់ពលករបញ្ជូនត្រលប់ និងផ្តល់កិត្តិយសប្រគល់លិខិតថ្លែងអំណរគុណ របស់គណៈកម្មាធិការជាតិ ដល់តំណាងក្រុមហ៊ុន **សុខ ស្រេង** ដែលបានផ្តល់ទីតាំងក្នុងការបំពេញការងារ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

## ២.៤. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៧០**លើក មានអ្នកចូលរួមសរុប ១.៨០៤នាក់ (ស្រី **៦៧៦**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៤២លើក ក្រសួងអប់រំ យុវជន និងកីឡា ០៤លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០២លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២២លើក។ (**ឧបសម្ព័ន្ធ១**)

# III. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្ស ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិ ផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួន នៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ជាប្រចាំ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅត្រីមាសទី២ ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...............ខែ..........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី..៣០....ខែ..១១...ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## ការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៧០លើក) មនុស្សចំនួន ១.៨០៤នាក់ (ស្រី ៦៧៦នាក់)

| **ស្ថាប័ន សម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ) | សម្របសម្រួលចំនួន ៤២លើក អ្នកចូលរួមចំនួន ៣២៨នាក់ (ស្រី ២០៦នាក់)<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អញ្ជើញចូលរួម៖<br>- បើក និងបិទវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារពីការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារវគ្គ២ ក្រោមកិច្ចសហការជាមួយអង្គការ Child Fund នៅសាលាខេត្តស្វាយរៀង។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពី "យន្តការ នៃការគ្រប់គ្រងមណ្ឌលទទួលពលករខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនត្រឡប់ និងការផ្សព្វផ្សាយសេចក្តីសម្រេចលេខ ១៦៨/១៧ សសរ និងសេចក្តីសម្រេចលេខ ២០៩/១៨ សសរ"នៅសាលប្រជុំសាលាក្រុមប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។<br>- កិច្ចប្រជុំពិនិត្យរបាយការណ៍ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- អបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុន សែន** នៅសាលមហោស្រពពិពណ៌កោះពេជ្រ។<br>- ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃបានប្រារព្ធពិធី អបអរសាទរខួបលើកទី១០៨ ទិវាសិទ្ធនារីអន្តរជាតិ ៨មិនា ឆ្នាំ២០១៩ ក្រោមប្រធានបទ "**ការលើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស**" ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន ៧០០នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ អគារទ។<br>- បានដឹកនាំគណៈប្រតិភូក្រសួងមហាផ្ទៃ ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តតាកែវ ក្រោមអធិបតីភាព ឯកឧត្តម កិត្តិកោសល្យបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំសាលាខេត្តតាកែវ។<br>- ជាអធិបតីភាព ថ្លែងសុន្ទរកថាបើកក្នុងអង្គសិក្ខាសាលា ស្តីពីការអនុវត្តបែបកុមារមេត្រី ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌដើម្បីការពារកុមាររងគ្រោះ និងកុមារជាសាក្សីនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទស មាសភាពចូលរួមក្នុងអង្គសិក្ខាសាលាអញ្ជើញមកពី ក្រសួងយុត្តិធម៌ តំណាងពីស្ថាប័នតុលាការ តំណាងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ តំណាងអគ្គស្នងការនគរបាលជាតិ អគ្គលេខាធិការគណៈមេធាវីកម្ពុជា តំណាងអង្គការ UNICEF តំណាងមេធាវីអន្តរជាតិ នាយកដ្ឋានការពារក្តីជនក្រីក្រមកពីគណៈមេធាវីកម្ពុជាអង្គការដៃគូពាក់ព័ន្ធ នគរបាលមានសមត្ថកិច្ចអនុវត្តការងារ សរុបប្រមាណ ៩០នាក់ នៅសណ្ឋាគារសុខាភ្នំពេញ។ |

- ជាអធិបតីភាពបើកនូវកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធអំពើជួញដូរមនុស្ស អំពើជួញដូរមនុស្ស ខេត្តសៀមរាប នៅសាលាខេត្តខេត្តសៀមរាប។
- ដឹកនាំក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ ចុះសាកសួរសុខទុក្ខ និងសំណេះសំណាលស្ត្រីជាប់ចោទទណ្ឌិត មានផ្ទៃពោះនិងកុមារនៅមណ្ឌលព្រៃស។

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

- កិច្ចរួមប្រជុំ ស្ដីពីការរៀបចំសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ អគារ១។
- ពិធីចុះហត្ថលេខាលើអនុស្សរណៈរវាងក្រសួងមហាផ្ទៃ និងអង្គការ IJM ក្រោមអធិបតីភាព ឯកឧត្តម សន្តិបណ្ឌិត **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ អគារ១។
- កិច្ចប្រជុំ ស្ដីពីគណៈកម្មាធិការលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារ នៅក្រសួងកិច្ចការនារី។
- កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ នៅវិមានសន្តិភាព រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីស្ត្រីកម្ពុជា។
- កិច្ចប្រជុំលើទម្រង់របាយការណ៍បូកសរុបសកម្មភាព និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩។
- ចូលរួមសម្ពោធមណ្ឌលសំចតពលករ នៅប៉ោយប៉ែតខេត្តបន្ទាយមានជ័យ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**

- មន្ត្រីក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចំនួន ០២រូប បានចូលរួមក្នុងកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា ដឹកនាំដោយ លោកជំទាវ **ស៊ិន សិរី** អគ្គស្នងការកាយឫទ្ធិស្ត្រីកម្ពុជា និងសហការចូលរួមពីក្រសួងកិច្ចការនារី បានផ្សព្វផ្សាយពីស្ថានភាពទូទៅនៃអំពើជួញដូរមនុស្ស ដែលផ្តោតសំខាន់លើបទល្មើសស៊ីឈ្នួលពពោះជំនួស ដល់លោកមេឃុំ នាយិកា អ្នកគ្រូ សិស្សានុសិស្សសាលាសង្គម និងមាតាបិតាសិស្ស សរុបចំនួន ៨៥នាក់ (ស្រី ១៤នាក់ សិស្សស្រី ៧១នាក់)។
- មន្ត្រីចំនួន០២រូប នៃក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមក្នុងកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា នៅភូមិស្រីប្រសើរ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ដែលដឹកនាំដោយលោកជំទាវ **ម៉ែន នារីវុឌ្ឍី** ស្នងការទំនាក់ទំនងសាធារណៈនៃកាយឫទ្ធិកម្ពុជា និងមានការចូលរួមពីក្រសួងកិច្ចការនារី និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្សព្វផ្សាយពីស្ថានភាពទូទៅ នៃអំពើជួញដូរមនុស្ស ដែលផ្តោតសំខាន់លើការធ្វើចំណាកស្រុក និងបទល្មើសស្ត្រីស៊ីឈ្នួលពពោះជំនួស ដល់លោកមេឃុំស្លា សិស្សានុសិស្សសាលាបឋម សិក្សា **ហ៊ុន សែន** បណ្ឌិត និងសមាជិកាក្រុមកាយឫទ្ធិស្ត្រីកម្ពុជា សរុបចំនួន ៦៩នាក់ (ប្រុស០១នាក់)។
- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំមន្ត្រីចំនួន ០៣រូប ទៅចូលរួមកម្មវិធីសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពលើក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការរៀបចំផែនការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២០ ក្រោមអធិបតីភាព ឯកឧត្តម ប៊ូ ជុំសេរី អនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការ នៅក្រសួងអប់រំ យុវជន និងកីឡា។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**

- ក្រុមទំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមេត្រីអន្តរជាតិ ចុះសួរសុខទុក្ខស្ត្រីរកស៊ីពពោះជំនួយ មានទីលំនៅខេត្តកណ្តាល ដែលបានសម្រាលកូនប្រុសអាយុទើបតែ២ខែ។
- បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកែប ដឹកនាំកិច្ចប្រជុំដោយ លោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ្នកចូលរួមចំនួន១៧នាក់ ស្រី០៥នាក់។
- បានចុះទៅពិនិត្យតាមដានការសាងសង់មណ្ឌលសំចតសម្រាប់ទទួលជនងាយរងគ្រោះ នៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។
- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលសង្គ្រោះបឋមផ្លូវចិត្តដល់ជនរងគ្រោះ នៅសណ្ឋាគារ CAMBODIANIA រាជធានីភ្នំពេញ។
- បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការការពារជនរងគ្រោះ ដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម ឯក ក្រិត្យ រដ្ឋលេខាធិការ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** បានអញ្ជើញចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា៖
  - ត្រៀមដើម្បីចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅក្រសួងមហាផ្ទៃអគារV។
  - ស្តីពីការចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅទីស្តីការ នាយករដ្ឋមន្ត្រី (វិមានសន្តិភាព)។
  - សិក្ខាសាលា អន្តរក្រសួង ស្ថាប័ន ឆ្លុះបញ្ចាំង ស្តីពី ការអនុវត្តល្អនៃការចូលរួមរបស់កុមារ ក្នុងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ និងការអភិវឌ្ឍគម្រោងកម្មវិធីរៀបចំដោយអង្គការសម្ព័ន្ធសិទ្ធកុមារកម្ពុជា សហការ ជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។
  - កិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៨ រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅខេត្តកំពង់ចាម។
  - កិច្ចប្រជុំជ្រើសរើសប្រធានបទ សម្រាប់រៀបចំពិធីមិទ្ទិញអបអរសាទរខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
  - សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មានការចូលរួមពីមន្ត្រីរបស់ស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ សរុបចំនួន ១៤០នាក់ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។

| | |
|---|---|
| | - លោកអនុប្រធានក្រុមជំនួយកិច្ចការ និងមន្ត្រីបច្ចេកទេសចំនួន ០១រូប បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការងារបឋម ស្តីពីការឆ្លើយតបបែបយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មហាអនុតំបន់មេគង្គ ដោយមានការចូលរួមពីមន្ត្រីរបស់ស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ ប្រមាណ ៣០នាក់ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**<br>- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាគម្រោង ស្តីពីការរៀបចំផែនការការងាររបស់ កម្មវិធីត្រីកោណ ក្នុងតំបន់អាស៊ាន សម្រាប់ឆ្នាំ២០១៩ និងការត្រួតពិនិត្យវឌ្ឍនភាព ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។**ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**<br>- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាគម្រោង ស្តីពីការរៀបចំផែនការការងាររបស់ កម្មវិធីត្រីកោណ ក្នុងតំបន់អាស៊ាន សម្រាប់ឆ្នាំ២០១៩ និងការត្រួតពិនិត្យវឌ្ឍនភាព ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** បានអញ្ជើញចូលរួម៖<br>○ ដឹកនាំកិច្ចប្រជុំ ស្តីពីការពិភាក្សា និងរៀបចំកម្មវិធី និងធ្វើគម្រោងចំណាយផ្សេងៗ សម្រាប់ធ្វើបទបង្ហាញទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធប្រមូលព័ត៌មាន ដៃគូអភិវឌ្ឍន៍លើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីតំណាងអង្គការចាប់ដៃ និងអង្គការវីនរ៉ក ប្រចាំកម្ពុជា។<br>○ កិច្ចប្រជុំ ក្រុមពិភាក្សាទី៨ នៅសាលប្រជុំអាគារពន្ធនាគារ លើប្រធានបទការគ្រប់គ្រងជនជាប់ឃុំ ដើម្បីធានាបានសន្តិសុខ សុវត្ថិភាព សុខភាព មនុស្សធម៌ អប់រំកែប្រែ ឈានទៅធ្វើសមាហរណកម្មក្នុងសង្គម មានភាពងាយស្រួល និងប្រឈមអ្វីខ្លះ? ដោយមានការដឹកនាំពី ឯកឧត្តម **ប៉ាវ ហមផាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន អ្នកចូលរួមចំនួន៣៥នាក់ ស្រី០៤នាក់។<br>○ កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស) ដែលប្រព្រឹត្តទៅនៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**<br>○ កិច្ចប្រជុំដើម្បីត្រៀមរៀបចំឯកសារសម្រាប់ទៅចូលរួមកិច្ចប្រជុំ COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាព លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅទីស្តីការក្រសួងកិច្ចការនារី។<br>○ កិច្ចពិភាក្សាស្តីពី ការងារប្រព័ន្ធទិន្នន័យ Database ជាមួយអង្គការ វីនរ៉ក់ និងសម្ព័ន្ធចាប់ដៃ។<br>○ វគ្គបណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំជាស្ត្រី ក្រោមប្រធានបទ **"Women's Leadership: A Catalyst for Gender Equality and Inclusive Growth"** ដែលប្រព្រឹត្តទៅនៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមកិច្ចសហការ ក្រសួងកិច្ចការនារី ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាពចូលរួមជាស្ត្រី និងបុរសថ្នាក់ដឹកនាំមកពីក្រសួងចំនួន៩ (ស្រី ២៣នាក់ ប្រុស ០១នាក់)។<br>- ប្រធានក្រុមជំនួយការ(ស្តីទី) និងមន្ត្រីបច្ចេកទេសចំនួន ០២រូបបានចូលរួម៖<br>○ សិក្ខាសាលាវាយតម្លៃទៅលើគម្រោងពង្រឹងកិច្ចអន្តរាគមន៍ ទៅលើពលករខ្មែរមុននឹងធ្វើចំណាកស្រុក ដែលត្រូវបានរៀបចំដោយអង្គការ VARITE។ |

○ កិច្ចប្រជុំពិនិត្យ ពិភាក្សា និងត្រៀមរៀបចំឯកសារសម្រាប់ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត លើកទី១៣ និងពិនិត្យមើលឡើងវិញនូវសកម្មភាពស៊ើបអង្កេតរួមគ្នារវាងប្រទេសសមាជិកទាំង៦) COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណៈរដ្ឋប្រជាមានិតចិន ក្រោមអធិបីភាពលោកជំទាវ **សាន្ត អរុណា** រដ្ឋលេខាធិការ នៅក្រសួងកិច្ចការនារី។

- ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំមន្ត្រីបច្ចេកទេសលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះទៅបំពេញបេសសកម្មនៅទីក្រុងប៉ោយប៉ែត ដើម្បីធ្វើការសិក្សាពីតម្រូវការបច្ចេកទេសផ្នែកព័ត៌មានវិទ្យា សម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចតសម្រាប់ទទួលពលករ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លិខិតចេញ ចំនួន ១០ច្បាប់ និងលិខិតចូល ចំនួន ១០ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ចំនួន ១៥ច្បាប់ លិខិតចូល ចំនួន ២៣ច្បាប់។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងបូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងរបាយការណ៍ត្រីមាសទី១ របស់ គ.ជ.ប.ជ។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី(wiki)។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- ស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា Convert ជា PDF បានចំនួន ៧០ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។
- បោះពុម្ពសៀវភៅក្ដាក់ងារជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស ដាក់ជូនលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។
- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធវីគី(wiki) បានចំនួន ២៨ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាពចូលក្នុងប្រព័ន្ធអ៊ីនធើណេតក្នុងបណ្តាល័យវីគី(wiki)គ.ជ.ប.ជ បានចំនួន ៤៤សកម្មភាព។
- អាប់ឡូតព័ត៌មានចូលគេហទំព័រ គ.ជ.ប.ជ ធ្វើលិខិតថ្លែងអំណរគុណជូនដល់អង្គការ ក្រុមហ៊ុន ស្ថាប័នរដ្ឋ ស្ថានីយ៍ទូរទស្សន៍ តារាចម្រៀង ដែលបានចូលរួមសហការរៀបចំទិវាជាតិ ១២ធ្នូ ខួបលើកទី១២ ឆ្នាំ២០១៨។
- កែសម្រួលលើមាតិកាក្នុង Project: terms.ncct.gov.kh និងបកប្រែខ្លឹមសារនៅក្នុង keyword ដែលអង្គការវីនរ៉ក់ផ្តល់អោយ និងដាក់ Keyword ទៅក្នុងវីគី(wiki) terms.ncct.gov.kh សម្រាប់ផ្តល់ភាពងាយស្រួលទាញយកមកប្រើប្រាស់ពេលក្រោយ។
- ដោះស្រាយបញ្ហា Error មួយចំនួននៅក្នុង terms.ncct.gov.kh និងត្រួតពិនិត្យមើលការងារទូទៅនៅក្នុង wiki.ncct.gov.kh។
- ចុះបេសកម្មទៅកាន់ក្រុងប៉ោយប៉ែតដើម្បីធ្វើការសិក្សាពីតម្រូវការផ្នែកព័ត៌មានវិទ្យាសម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចត សម្រាប់គ្រប់គ្រងព័ត៌មានលំហូរទេសន្តប្រវេសន៍។

| | |
|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | - បានចូលរួមប្រជុំស្តីពីការពិភាក្សារកវិធានការលើការគ្រប់គ្រងលំហូរពលករកម្ពុជា( លំហូរចេញ-លំហូរចូល ) អំឡុងពេលពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ។<br>- បានរៀបចំប្រជុំអន្តរក្រសួង ស្តីពីការរៀបចំផែនសកម្មភាពការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០១៣។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការប្រឹក្សាយោបល់លើការវាយតម្លៃពាក់កណ្តាលគម្រោង នៃការអនុវត្តន៍ផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ។<br>- បានចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ របស់ក្រុមការងារការពារជនរងគ្រោះ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចាត់គ្រូឧទ្ទេសចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ចំនួន ០២លើក នៅខេត្តកណ្តាល រៀបចំដោយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា អ្នកចូលរួមចំនួន ៧៥នាក់ ស្រី ២២នាក់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២២លើក អ្នកចូលរួមសរុបចំនួន ១.៤០១នាក់ (ស្រី ៥៤៨នាក់)** | |
| ខេត្តបាត់ដំបង | - បានចូលរួមធ្វើជាអ្នកសម្របសម្រួលកម្មវិធី ស្តីពីការយល់ដឹងជាសាធារណៈអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកត្តារុញច្រាន ព្រមទាំងកត្តាអូសទាញនៃការធ្វើចំណាកស្រុក នៅស្រុកថ្មគោល។ |
| ខេត្តកំពត | - លោកនាយ-នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមសិក្ខាសាលាស្តីពី "ការជួញដូរមនុស្សនាសម័យទំនើប" ដែលរៀបចំឡើងដោយអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ ( H0PE for JUSTICE )។ |
| ខេត្តព្រះសីនុ | - ក្រុមលេខាធិការដ្ឋានខេត្ត សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE)រៀបចំកិច្ចប្រជុំតុមូល ស្តីពីការការពារកុមារសុវត្ថិភាពកុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើចំណាកស្រុកខុសច្បាប់ តាមប្រព័ន្ធអ៊ិនធឺណិត នៅសណ្ឋាគារឆ្នេរថ្មី អ្នកចូលរួមចំនួន ៤៧នាក់ ស្រី ២០នាក់។ |
| ខេត្តព្រៃវែង | - លេខាធិការដ្ឋាន គ ជ.ប.ខ.និងគណៈកម្មាធិការពិគ្រោះយោបល់ បានប្រជុំប្រចាំខែនៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីផ្សព្វផ្សាយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញ ប្រឆាំងការជួញដូរមនុស្សជូនដល់អង្គប្រជុំ ជាពិសេស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួនតាមរយៈ ពិធីមង្គលការ ពិធីបុណ្យ និងពិធីកម្សាន្តផ្សេងៗ ។ល។ |
| ខេត្តកោះកុង | - សមាជិកលេខាធិការដ្ឋានខេត្ត គ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់យុត្តិធម៌អនីតិជន អ្នកចូលរួមចំនួន ៣៧នាក់ ស្រី០៥នាក់ នៅខេត្តកំពត។<br>- បានរៀបចំកិច្ចប្រជុំក្រុមជួយខ្លួនឯង ផ្តោតលើប្រធានបទ អនុស្សរណៈយោគយល់គ្នារវាងប្រទេសកម្ពុជា និងប្រទេសថៃ ក្នុងការបញ្ជូនពលករទេសន្តរប្រវេសន៍ ក្នុងសហគមន៍ចំនួន៥ អ្នកចូលរួមចំនួន ៩៣នាក់ ស្រី ៦៦នាក់។ |
| ខេត្តប៉ៃលិន | - បានរៀបចំកិច្ចប្រជុំ ពិនិត្យពិភាក្សាសេចក្តីព្រាង ស្តីពីការសម្រួលសមាសភាព និងរបាយការណ៍ប្រចាំខែមករា អ្នកចូលរួមចំនួន ៣២នាក់ ស្រី០៦នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ នៅមន្ទីរកិច្ចការនារីខេត្តប៉ៃលិន។ |

| | |
|---|---|
| **ខេត្តកំពង់ធំ** | - លោកស្រីស្នងការរងទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានចូលរួមប្រជុំប្រចាំខែមករារបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅសាលប្រជុំសាលាខេត្ត។<br>- លោកស្រីស្នងការរងទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការជួញដូរមនុស្ស នាសម័យទំនើប នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការថែទាំជំនួសចំពោះកុមាររងគ្រោះដោយអំពើហិង្សា ការជួញដូរ ការរំលោភសេពសន្ថវៈ ពលកម្មធ្ងន់ធ្ងរ ការធ្វើចំណាកស្រុក និងកុមារកំព្រា អ្នកចូលរួមចំនួន ៦០នាក់ ស្រី ២១នាក់ នៅខេត្តកែប។ |
| **ខេត្តស្វាយរៀង** | - បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩ អ្នកចូលរួមចំនួន ២១៦នាក់ ស្រី ៣៨នាក់។<br>- បានបញ្ជូនមន្ត្រីនគរបាលជាន់ខ្ពស់ចំនួន០២នាក់ ទៅចូលរួមសិក្ខាសាលា ស្តីពីការជួញដូរមនុស្សនាសម័យទំនើប នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ |
| **ខេត្តតាកែវ** | - បានប្រជុំក្រុមការងារថ្នាក់ស្រុក នៅក្រុងដូនកែវ ស្តីពីយន្តការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភសន្ថវៈ អ្នកចូលរួមចំនួន ៥៦នាក់ ស្រី ៤០នាក់។<br>- លោកស្រី អភិបាលរងខេត្ត បានដឹកនាំសម្របសម្រួលប្រជុំជាមួយក្រុមការងារថ្នាក់ក្រុងដូនកែវ ស្តីពីយន្តការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភសន្ថវៈ អ្នកចូលរួមចំនួន ៤០០នាក់ ស្រី ២០៤នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីមូលដ្ឋានគ្រឹះជំនាញចិត្តសង្គមក្នុងការជួយដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង។<br>- បានចូលរួមកិច្ចប្រជុំ គ.ក.ស.ក ប្រចាំខែមករា ០១លើក អ្នកចូលរួមចំនួន ២៥នាក់ ស្រី ១១នាក់។ |
| **ខេត្តសៀមរាប** | - បានបើកកិច្ចប្រជុំលេខាធិការដ្ឋាន គ.ខ.ប.ជ ប្រចាំខែកុម្ភៈ អ្នកចូលរួមចំនួន ៥៧នាក់ ស្រី ២៨នាក់។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន ក.ខ.ប.ជ បានដឹកនាំក្រុមការងារបច្ចេកទេសទាំង៦ ទទួលជួបពិភាក្សាដើម្បីផ្តល់ព័ត៌មាន និងអនុសាសន៍ពាក់ព័ន្ធយេនឌ័រ សម្រាប់គាំទ្រលើការរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៩-២០២៣ ជាមួយអ្នកជំនាញស្រាវជ្រាវ របស់អង្គការ UN WOMEN នៅសាលាខេត្តសៀមរាប។<br>- បានចូលរួមសិក្ខាសាលា ពង្រឹងសមត្ថភាពក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅវិទ្យាល័យសម្តេចឪ ក្រុងសៀមរាប។<br>- គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អ្នកចូលរួមចូលរួម ២៥០នាក់ នៅសាលាខេត្តសៀមរាប។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងបណ្តាស្រុកទាំង៨។ |
| **ខេត្តកំពង់ស្ពឺ** | - ប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ អ្នកចូលរួមចំនួន ១៧៥នាក់ ស្រី ៣៣នាក់។ |